# ថ្ងៃចូលរៀនលើកដំបូង និង តម្លៃគ្រូ

កាលខ្ញុំអាយុបាន ៦ ឆ្នាំ ខ្ញុំប្រើល្បិចដើម្បីឲ្យឆាប់បានទៅរៀនមុនពេលគ្រប់អាយុ ។ ក្នុងសម័យនោះ ពុំទាន់មានថ្នាក់មត្តេយ្យនៅឡើយទេ ។ កូនក្មេងទាល់តែអាយុ ៧ ឆ្នាំ ទើបឪពុកម្តាយឲ្យទៅរៀន ។ នៅពេលចូលរៀនលើកដំបូងម្តងៗ កុមារខ្លះ ខ្លាចសាលា យំស្រែកមិនចង់ចូលរៀន ។ ឪពុកម្តាយខ្ញុំ ប្រគល់ភារៈឲ្យម្តាយមីងខ្ញុំគឺ អ្នកមីងសាម៉ុឌី ជាអ្នកសម្រេចតើពេលណាខ្ញុំអាចចូលរៀនបាន ព្រោះខ្ញុំចេះតែទារទៅសាលារៀន ។ កាលនោះ អ្នកមីងសាម៉ុឌី ជាអ្នកគ្រូ បង្រៀនថ្នាក់ឧត្តមដ្ឋាន[16] នៅសាលាបឋមសិក្សាស្នាយពល ។ អ្នកមីងជាអ្នកគ្រូក្រមុំដែលមានរូបសម្ផស្សស្អាតជាងគេនៅក្នុងភូមិ ។ តាមពិត ឪពុកម្តាយខ្ញុំចង់ឲ្យខ្ញុំទៅរៀនដែរ តែចង់ឲ្យខ្ញុំរង់ចាំដល់អាយុគ្រប់ ៧ ឆ្នាំសិន ។

ថ្ងៃមួយ នៅពេលម្តាយមីងខ្ញុំកំពុងអង្គុយបោកខោអាវ ខ្ញុំរត់ទៅជិតគាត់ ហើយស្រែកថា "ហេ ហេ អ្នកមីងឥឡូវខ្ញុំលូកដៃដល់ត្រចៀកហើយ" ។ អ្នកមីងអស់សំណើច ព្រោះតាមធម្មតានៅជំនាន់នោះ ក្មេងៗអាចចាត់ទុកថាធំល្មម អាចទៅរៀនបាន នៅពេលដែលពួកគេអាចលើកដៃស្តាំដាក់ពីលើក្បាល ហើយលូកទៅដល់ត្រចៀកខាងឆ្វេងបាន ។ ក៏ប៉ុន្តែ ខ្ញុំមិនធ្វើយ៉ាងដូច្នោះទេ ខ្ញុំលូកដៃស្តាំពីក្រោយក្បាលទៅប៉ះត្រចៀកឆ្វេងតែម្តង ដោយមិនដាក់ដៃលើក្បាលដូចអ្នកឯទៀតទេ ។ ម្តាយមីងខ្ញុំ ឲ្យខ្ញុំធ្វើកាយវិការនេះម្តងទៀត ហើយនៅទីបំផុតគាត់សន្យាថា នាំខ្ញុំទៅសាលារៀននៅព្រឹកថ្ងៃស្អែក ។ ព្រឹកឡើង អ្នកមីងឲ្យខ្ញុំឡើងជិះកង់ នៅខាងក្រោយ ហើយគាត់ក៏ឌុបយកខ្ញុំទៅរៀន ។ ខ្ញុំមានក្តីរំភើបជាអនេក ដោយបានទៅរៀនផង

[16] ថ្នាក់ឧត្តមដ្ឋាន ជាថ្នាក់បញ្ចប់បឋមសិក្សា និង ត្រូវប្រឡងចូលរៀនអនុវិទ្យាល័យ ។

និង បានជិះកង់ជាមួយអ្នកគ្រូក្រមុំ ដែលជាបវរកញ្ញាមួយរូបប្រចាំភូមិរបស់យើងផង ។

ខ្ញុំមានការសប្បាយរីករាយជាខ្លាំង ក្នុងការសិក្សារបស់ខ្ញុំនៅសាលាបឋមសិក្សាស្នាយពល ។ នៅពេលយើងរៀនដល់ថ្នាក់មធ្យមដ្ឋានទី១(ថ្នាក់ទី៥ថ្មី) យើងចាប់រៀនភាសាបារាំង ។ នៅពេលចូលរៀនអនុវិទ្យាល័យ មុខវិជ្ជាទាំងអស់លើកលែងតែមុខវិជ្ជាខ្មែរចេញ សុទ្ធតែជាភាសាបារាំង ។ ចេះភាសាបារាំង គេចាត់ទុកជាអ្នកចេះដឹង និង ជាបញ្ញវន្ត ។ ខ្មែរយើងមួយចំនួនច្រើននិយាយខ្មែរលាយបារាំង ដើម្បីបង្ហាញថា ជាអ្នកចេះដឹង ។ គួរកត់សម្គាល់ថានៅជំនាន់នោះ ប្រពៃណីខ្មែរយើងឲ្យតម្លៃខ្លាំងណាស់ដល់លោកគ្រូអ្នកគ្រូ ។ កូនសិស្សមានការគោរពកោតខ្លាចគ្រូជាទីបំផុត ។ នៅក្នុងសង្គម គ្រូត្រូវបានចាត់ទុកជាឪពុកម្តាយទីពីរ បន្ទាប់ពីឪពុកម្តាយបង្កើត ។ តាមឋានានុក្រមនៃការគោរព គេគោរពព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ មាតា បិតា បន្ទាប់មក គេគោរពគ្រូបាធ្យាយ ។ សូម្បីតែក្នុងសិល្បៈប្រពៃណីមួយចំនួន ក៏មានការគោរពគ្រូមុននឹងសម្តែងដែរ ។ ដោយសារប្រពៃណីគោរពគ្រូយ៉ាងនេះ ធម្មតាការងាររបស់អ្នកគ្រូ លោកគ្រូ មិនមានការលំបាកឡើយ ។ កូនសិស្សខ្លាចគ្រូ គោរពគ្រូ និង ស្តាប់គ្រូខ្លាំងណាស់ ។ ក៏ប៉ុន្តែនៅមានលោកគ្រូអ្នកគ្រូខ្លះ ប្រើអំពើហឹង្សា លើសិស្សទៀតផង ។ ក្នុងថ្នាក់រៀនខ្លះ លោកគ្រូកាចត្រៀមរំពាត់ផ្តៅពីរ ឬ បីដើម ។ លោកគ្រូដែលកាចខ្លាំង ប្រើជន្ទល់បង្គួច វាយលើសិស្សណាដែលខ្ជិលច្រអូសមិន ចេះមេរៀន ឬ មានអាកប្បកិរិយាមិនគប្បី ។ តែទោះបីជាលោកគ្រូ អ្នកគ្រូកាចសម្បើមយ៉ាងណាក៏ដោយ ក៏កូនសិស្សនៅតែដឹងគុណលោកគ្រូ អ្នកគ្រូ អស់មួយជីវិត ។

មួយឆ្នាំក្រោយមក ម្តាយមីងរបស់ខ្ញុំ ត្រូវរៀបការជាមួយមន្ត្រីគយម្នាក់ឈ្មោះ អ៊ុក ថន ដែលមានស្រុកកំណើតនៅភូមិស្នាយពលក្រោម ។ ខ្ញុំក៏មិនបាន

ដឹងថាអ្នកមីង និង លោកពូមានទំនាក់ទំនងគ្នាតាំងពីពេលណា និង យ៉ាងដូចម្តេចទេ ព្រោះម្នាក់នៅបង្រៀនឯស្វាយពល និង ម្នាក់ទៀតកំពុងបំពេញភារកិច្ចនៅឯទីក្រុងឯណោះ ។ បន្ទាប់ពីរៀបការភ្លាមមក ម្តាយមីងខ្ញុំបានរើទៅនៅជាមួយស្វាមីរបស់គាត់ឯក្រុងភ្នំពេញ ។

ចាប់ពីពេលដែលឪពុកម្តាយខ្ញុំរៀបអាពាហ៍ពិពាហ៍មក ប្រពៃណីរបស់អ្នកស្រុកយើង មានការប្រែប្រួលច្រើន ។ ឥឡូវ គេមិនចាំបាច់ឲ្យកូនកម្លោះមកនៅបំរើគ្រួសារខាងស្រីជាមុននោះទៀតទេ ។ បើត្រូវរ៉ូវគ្នា គេអាចរៀបចំពិធីអាពាហ៍ពិពាហ៍បាន ។ ក៏ប៉ុន្តែ ជាការចាំបាច់គេត្រូវរកគ្រូហោរាគន់គូរ ត្រួតពិនិត្យ ខែ ឆ្នាំ តើបើបានគ្នាជាគូរស្រករអាចល្អ ឬ អាក្រក់? ពិសេសទៅទៀត គេរកលោកអាចារ្យជ្រើសរើសពេលវេលាសម្រាប់រៀបមង្គលការ ដើម្បីឲ្យគូស្វាមី មានសិរីសួស្តី និង ជោគជ័យក្នុងជីវិតទៅអនាគត ។ ទោះបីប្រពៃណីរបស់យើង មានការវិវឌ្ឍខ្លះក៏ដោយ ក៏គេនៅរៀបចំពិធីអាពាហ៍ពិពាហ៍ក្នុងរយៈពេលបីថ្ងៃ បីយប់ដូចពីមុនដែរ ។

ប៉ុន្មានថ្ងៃមុនពេលពិធីមង្គលការរបស់ម្តាយមីងខ្ញុំចាប់ផ្តើម ម្នាក់ៗរវល់ញាប់ដៃ ។ ប្រុសៗនាំគ្នាសង់រោង ឯស្ត្រីៗនាំគ្នាវេចនំ មាននំអន្សម នំគម នំបត់ តាមទម្លាប់ ។ គេសង់រោងធំសម្រាប់ពិធីជប់លៀង និង រោងតូចមួយទៀតជារោងសម្រាប់ទទួលកូនកម្លោះ ដែលត្រូវស្នាក់នៅក្នុងរយៈពេលនៃពិធីទាំងមូល និងដែលជាទីកន្លែងសម្រាប់អ្នកភ្លេង និង អ្នកចំរៀង សម្តែងសិល្បៈប្រពៃណីផង ។ នៅខាងក្រោយផ្ទះ ពួកកម្មករនាំគ្នាជីករណ្តៅ ធ្វើចង្ក្រានខ្វះត្នោត ទុកសម្រាប់ចំអិនម្ហូបអាហារ ដែលគេត្រូវការផ្គត់ផ្គង់ដល់ភ្ញៀវក្នុងរយៈពេលបីថ្ងៃ បីយប់នៃពិធីរួមទាំងពិធីជប់លៀងធំនៅថ្ងៃបង្ហើយផង ។ ឃើញគេធ្វើរោងបាយ និង ជីករណ្តៅយ៉ាងនេះ កាលនោះខ្ញុំមានអាយុទើបតែបាន ៧ ឆ្នាំ ខ្ញុំនឹកឆ្ងល់ក្នុងចិត្តថា ហេតុដូចម្តេចបានជាគ្មានអ្នកណាបើកហាងដែលមានបន្ទប់ធំទូលាយ មានតុកៅអីស្រេច ត្រៀមជួល

ក្នុងពេលមង្គលការ ដោយមិនចាំបាច់ធ្វើរោង ឬ ជីកដីធ្វើអ្វី?កាលនោះ ខ្ញុំអត់ដឹងថា នៅទីក្រុងភ្នំពេញ គេមានសណ្ឋាគារ ឬ ភោជនីយដ្ឋានធំៗ ដែលគេអាចជួលកន្លែងសម្រាប់រៀបចំពិធីផ្សេងៗរួចទៅហើយ ។